C21

C21

# ពាណិជ្ជកម្មដំណាំស្វាយសំរាប់កសិករ



រៀបចំដោយមានការចូលរួមពីអង្គការ សន្តិសេនា សមាគមមនុស្សចាស់ពោធិធំ អង្គការចិត្តធម៌ និង អង្គការ ស៊ី អារ អែស កម្មវិធីកសិកម្ម

ដក់ស្រង់ពីឯកសារឈើហូបផ្លែរបស់អង្គការ ប៉ាដិក ស៊ីដសេ និង សាលាជាតិកសិកម្មព្រែកលៀប

B0

# មាតិការ

ទំព័រ

១- សេចក្តីផ្តើម......................................................................................០១

២- ការជ្រើសរើសពូជ.................................................................................០១

៣- ការបណ្តុះកូន .......................................................................................០៣

ក. ជ្រើសរើសទីតាំងថ្នាល..........................................................................០២

ខ. ការរៀបចំថ្នាល....................................................................................០២

គ. ការបណ្តុះកូនស្វាយ...............................................................................០៣

ឃ. ការផ្សាំក្នុងថង់.....................................................................................០៤

៤- ការដាំដុះ.............................................................................................០៥

ក. ការជ្រើសរើសទីកន្លែងដាំដុះ.................................................................. ...០៥

ខ. របៀបជីករណ្តៅ....................................................................................០៥

គ. ការដាក់ជីក្នុងរណ្តៅ.............................................................................. ០៦

ឃ. ការដាំកូនស្វាយ....................................................................................០៧

៥- ការថែទាំ.............................................................................................០៨

ក. ការដាក់ជ...........................................................................................០៨

ខ. ការស្រោចទឹក.......................................................................................០៨

គ. ការតាក់តែងមែក...................................................................................១០

ឃ. ការការពារជម្ងឺ និង សត្វល្អិតចង្រៃ.........................................................១១

៦- ការប្រមូលផល......................................................................................១១

៧- ការបន្តពូជ............................................................................................១២

ក. ការបន្តពូជដោយគ្រាប់............................................................................១២

ខ. ការបន្តដោយសាកមែក.......................................................................១២-១៣

## ១-សេចក្ដីផ្ដើម

ស្វាយជារុក្ខជាតិមួយប្រភេទដែលអាចដាំដុះលើដីច្រើនប្រភេទបាននៅក្នុងប្រទេសកម្ពុជាវាមានអាយុកាលប្រហែលពី២០ ទៅ ៤០ឆ្នាំ វាផ្ដល់ផ្លែក្នុងរយៈពេលប្រហែលពី៤ ទៅ ៥ឆ្នាំក្រោយ ពេលដាំដុះអាស្រ័យលើប្រភេទពូជ។ ស្វាយមានប្រយោជន៍ច្រើន យ៉ាងដូចជាៈ- ផ្លែសំរាប់ហូប ដំណាប់ ស្លឹកខ្ចីធ្វើអន្លក់ ស្លឹកទុំជ្រុះធ្វើជីកំប៉ុស្តិ៍ ដើមធ្វើជាសំណង់ អុសដុត ជាម្លប់ និង ជារបាំងខ្យល់ ។

## ២-ការជ្រើសរើសពូជ

ដើម្បីអោយទទួលបានផល ឆាប់ និង ខ្ពស់ យើងត្រូវផ្អែកលើលក្ខណៈសំគាល់មួយចំនួនដូចជា :- ផ្លែធំមានសាច់ច្រើន រស់ជាតិផ្អែម ធនជំងឺ និង សត្វល្អិតចង្រៃ ឆាប់ផ្លែ មានប្រភពច្បាស់លាស់ អាចដាំដុះបាននៅលើដីច្រើនប្រភេទ និង មានតំលៃខ្ពស់នៅទីផ្សារ ។



## ៣-ការបណ្តុះកូន

### ក. ជ្រើសរើសទីតាំងថ្នាល:

ទីតាំង និង ការរៀបចំថ្នាលជាកត្តាមួយដ៏សំខាន់សំរាប់ធ្វើអោយការដុះពន្លកនៃកូនដំណាំបានគង់វង់ក្នុងបរិមាណខ្ពស់ និង មានសុខភាពល្អនោះដូចជា ៖- ជិតប្រភពទឹក ដីទួលមិនលិចទឹក មានពន្លឺព្រះអាទិត្យគ្រប់គ្រាន់ និង ជាទីកន្លែងងាយស្រួលក្នុងការការពារ ។

### ខ. ការរៀបចំថ្នាល:

ត្រូវលើកដីថ្នាលអោយបានកំពស់២តឹក ទទឹង១ម៉ែត្រ និង បណ្តោយអាស្រយ័ទៅតាមប្រវែងជាក់ស្តែងដែលយើងចង់បាន កាប់ដីអោយម៉ត់ និង ហាលដីរយះពេលពី២ទៅ ៣ សប្តាហ៍ដើម្បីសំលាប់បាក់តេរី ឬ សត្វល្អិតចង្រៃផ្សេងៗ និង ជ្រោយដី រួចជ្រើសយកស្មៅចេញ ។



គ.ការបណ្តុះកូនស្វាយៈ

ត្រូវកាប់សំបកគ្រាប់ស្វាយដែលជ្រើសរើសរួចក្រោយពេលហូបពី២ ទៅ ៣ ថ្ងៃ និង កាំបិតមុត កប់គ្រាប់លើរងដែលបានរៀបហើយចំងាយប្រហែល២តឹកពីគ្រាប់មួយ ទៅគ្រាប់មួយ លុបដីម៉ត់ពីលើគ្រាប់ស្វាយអោយបានជិតល្អ គ្របកំណាត់ចំបើងដែល ចិញ្ច្រាំខ្លីៗពីលើ ស្រោចទឹកអោយសើមជាប្រចាំ។



ឃ. ការផ្សាំក្នុងថង់:

រយៈពេលមួយខែក្រោយបន្ទាប់ពីការបណ្ដុះក្នុងថ្នាលមកយើងអាចយកកូនស្វាយទៅផ្សាំក្នុងថង់បាន ប៉ុន្តែថង់ត្រូវច្រកដោយដីកំប៉ុស្តិ៍មួយភាគ អង្កាមមួយភាគ និងដីខ្សាច់មួយភាគ ។ កូនស្វាយដែលដុះលើសពីមួយដើមអាចបំបែកកូនចេញបាន រួចដាក់នៅក្នុងថង់ផ្សេងទៀត ។



## ៤-ការដាំដុះ

### ក.ការជ្រើសរើសទីកន្លែងដាំដុះ :

ស្វាយត្រូវដាំនៅកន្លែងណាដែលមានសុវត្ថិភាព ដីខ្ពស់មិនលិចទឹកតែមានសំណើមគ្រប់គ្រាន់ មានដីជាតិល្អ ឆ្ងាយពីដើមឈើធំៗដែលមានស្រាប់យ៉ាងហោចណាស់១០ម៉ែត្រ មានប្រភពទឹកនៅជិតងាយស្រួលក្នុងការស្រោចស្រពនៅពេលជួបប្រទះភាពរាំងស្ងួត ។

### ខ.របៀបជីករណ្តៅ:

រណ្តៅដាំស្វាយត្រូវមានទំហំសមល្មមគឺ ជំរៅមួយម៉ែត្រ បណ្តោយមួយម៉ែត្រ និងទទឹងមួយម៉ែត្រ គំលាតពីរណ្តៅមួយទៅរណ្តៅមួយយ៉ាងហោចណាស់១០ម៉ែត្រ ហើយត្រូវធ្វើយ៉ាងណាត្រូវកំណត់ជួរអោយបានប៉ះ និង ពន្លឺព្រះអាទិត្យស្មើគ្នា ។



## គ.ការដាក់ដីក្នុងរណ្តៅ:

ក្រោយពេលជីករណ្តៅរួច មុនពេលដាំត្រូវប្រមូលសំរាមដែលបានពីរុក្ខជាតិផេះ លាមកសត្វ ឬ ដីកំប៉ុស្តិ៍ដាក់ក្នុងរណ្តៅអោយបានច្រើនជាការប្រសើរ ព្រោះវាជាជីធម្មជាតិ ដែលផ្ទុកដោយអាហារធាតុចិញ្ចឹមច្រើនយ៉ាង ។





ឃ. <u>ការដាំកូនស្វាយ :</u>

ត្រូវពិនិត្យ និង អនុវត្តិអោយបានហ្មត់ចត់ដូចជា កូនស្វាយត្រូវមានអាយុយ៉ាងតិចពីរខែ មុនពេលដាំត្រូវចៀរថង់ថ្នម១ដោយកាំបិតមុតការពារកុំអោយបែកដី ដាំនៅពេលល្ងាច ដើម្បីអោយវាទទួលសំណើមពេលយប់ និង ស្រោចទឹកដើម្បីអោយឫសចាប់ជាប់និងដីថ្មី ។



## ៥-ការថែទាំ

### ក-ការដាក់ជីបំប៉នៈ

ជីបំប៉ន់ត្រូវដាក់ពីរដងក្នុងមួយឆ្នាំនៅរៀងរាល់ដើម និង ចុងរដូវវស្សា ដោយជីករណ្តៅ ពទ្ធ័ជុំវិញគល់ស្វាយចំងាយពីគល់ស្វាយទៅចុងមែកស្វាយដែលបែកចេញទៅ ខាងវែងជាងគេជុំវិញដើមជំរៅកន្លះម៉ែត្រទំហំពីពីរ ទៅ បួនតឹក ដាក់ជីធម្មជាតិ និង ជីគីមីសមាស ដែលមានធាតុ អ៊ុន ប៉េ ការ ។



ដាក់ជីបំប៉ន នៅដើមនិងចុងរដូវវស្សា

## ខ-<u>ការស្រោចទឹកៈ</u>

ការស្រោចទឹកគឺធ្វើឡើងដើម្បីបង្កលក្ខណៈងាយស្រួលដល់រោមជញ្ជក់របស់ឫស ស្រូប យកជីជាតិ ស្រោចទឹកបំប៉នអោយបានទៀងទាត់នៅពេលកូនស្វាយនៅតូច ស្រោចទឹក ពេលណាដែលយើងសង្កេតឃើញថាដំណាំស្វាយខ្វះជាតិទឹកនៅពេលវាពេញវ័យ ស្រោចទឹកបំប៉នអោយបានច្រើនជាប្រចាំនៅមុន និង ក្នុងពេលដំណាំស្វាយចេញផ្កា ។



## គ-ការតាក់តែងមែកៈ

ការតាក់តែងមែកគឺត្រូវធ្វើឡើងរៀងរាល់បួនឆ្នាំម្តងគឺក្រោយពេលប្រមូលផល រួចហើយមែកដែលត្រូវកាត់ចោលនោះមានដូចជាៈ- មែកចាស់ពេកគ្មានផ្លែ មែកសំយ៉ុងចុះ មែកដុះចាក់ទៅក្នុង មែកមានជំងឺ មែកមានដុះរុក្ខជាតិបញ្ញើរក្អែកនៅជាប់ ។ ការធ្វើរបៀបនេះដើម្បីអោយសុខភាពមែកល្អ ទទួយពន្លឺបានគ្រប់គ្រាន់ និង ស្រូបយកខ្យល់បានល្អធ្វើអោយស្វាយមានផ្លែធំ ។



មែកពីកំណើត



មែកបានតាក់តែង

ឃ. ការការពារជម្ងឺ និង សត្វល្អិតចង្រៃ:

យើងមានវិធីច្រើនយ៉ាង ដូចជាត្រូវដាក់កំបោរសរ សាចជូរខៀវ ស្អាន់ធ័រជុំវិញគល់ ការពារសត្វកន្ធេរ ប្រើថ្នាំគីមីពុលកសិកម្មម៉ាឡាចុងនៅពេលសត្វល្អិតបំផ្លាញ ផ្កា ឬ ក្តិប (រាល់ពេលដែលប្រើថ្នាំពុលគីមីត្រូវដាក់ផ្លាកសញ្ញាសំគាល់ជៀសវាងមានគ្រោះថ្នាក់ដល់ មនុស្ស និង សត្វ) មែកដែលមានជំងឺត្រូវកាប់រួចយកទៅកប់ ឬ ដុតចោល និង បំពក់ភ្លើង ដើម្បីអោយ ផ្សែងបណ្តេញសត្វល្អិត ។

## ៦-ការប្រមូលផល

ការប្រមូលផលដើម្បីរក្សាគុណផ្លែ និង មានតំលៃខ្ពស់នៅទីផ្សារ គឺនៅពេលផ្លែស្វាយ ជិតទុំ(ស្រគាល)គឺងាយស្រួលក្នុងការលើកដាក់សំរាប់ដឹកយកទៅទីឆ្ងាយ និង លក់ដូរ មិនត្រូវទុកអោយទុំពេកទេ ព្រោះវាត្រូវរងការបំផ្លាញពីសំណាក់សត្វជ្រឹង កណ្តុរ រុយចោះផ្លែ ជម្ងឺ និង ងាយរលួយ ។ ត្រូវប្រើឧបករណ៏ផ្សេងៗ ដូចជាឧបករណ៏ធ្វើពីដើមឬស្សីដើម្បី ថ្តក់ បេះផ្លែជៀសវាងការជ្រុះមកប៉ះដីផ្ទាល់ធ្វើអោយផ្លែគ្រាំ ឬ បែក ។



## ៧-ការបន្តពូជ

គេអាចបន្តពូជស្វាយបានតាមវិធីច្រើនយ៉ាង ប៉ុន្តែមាន វិធីតែពីទេដែលសមស្រប សំរាប់កសិករគឺមានដូចក្រោមៈ-

**ក.ការបន្តពូជដោយគ្រាប់ៈ**

ការបន្តពូជដោយគ្រាប់គឺជាវិធីមួយដែលល្អ និង ងាយស្រួលជាងគេ។ ការដាំដោយ គ្រាប់គឺលូតលាស់បានល្អ មានប្រពន្ធ័ឬសមាំ ធនទ្រាំជម្ងឺ និង មានអាយុកាលលូតលាស់វែង ប៉ុន្តែមានការចុះតូចនៃទំហំផ្លែពីមួយជំនាន់ទៅមួយជំនាន់ ចំពោះពូជមួយចំនួន។

**ខ.ការបន្តដោយសាកមែកៈ**

ការដាំស្វាយដោយមែកសាកឆាប់អោយផលគឺក្នុងរយៈពេល ពីពីរ ទៅបីឆ្នាំក្រោយ ពេលដាំតែប៉ុណ្ណោះ ប៉ុន្តែវាមានអាយុខ្លីជាងការដាំដោយគ្រាប់ព្រោះការលូតលាស់នៃឬស និង ដើមពុំមានតុល្យភាពគ្នា ។ ការសាកមែកត្រូវធ្វើតាមរបៀបដូចជា ជ្រើរើសមែកណាដែល មានសុខភាពល្អ ប្រវែងប្រហែលមួយម៉ែត្រ លាក់សំបកក្រឡឹងជុំវិញមែកដែលមាន ប្រវែង ទៅតាមទំហំនៃមែក បកសំបកចេញ កោសរំអិលទុកប្រហែពី១៥ ទៅ ៣០នាទី ចងថង់ផ្លាស់ស្ទិកដែលច្រកពេញដោយកំប៉ុស្តិ៍សើមជុំវិញមែកដែលកោសរួច ចងខ្សែរិតចំ កណ្តាលអោយណែន ស្រោចទឹកអោយសើមជាប្រចាំ និង កាត់យកទៅច្រកក្នុងដើមផ្សាំនៅ ពេលដែលយើងសង្កេតឃើញថាឬស ដែលដុះមានព័ណត្នោត ។

